**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ១០០០១ កសក

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ ២០១៦

**សូមគោរពជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ៖** របាយការណ៍ប្រចាំសប្តាហ៍ស្តីពី សភាពការណ៍ល្បឿនការងារប្រមូលផលដំណាំរដូវវស្សាឆ្នាំ២០១៦ និងល្បឿនការងារបង្កបង្កើនផលដំណាំរដូវប្រាំងឆ្នាំ២០១៦-២០១៧។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមអនុញ្ញាតជម្រាបជូន **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពដ៏ខ្ពង់ខ្ពស់មេត្តាជ្រាប អំពីសភាពការណ៍ល្បឿនការងារប្រមូលផលដំណាំរដូវវស្សាឆ្នាំ២០១៦ និងល្បឿនការងារបង្កបង្កើនផលដំណាំរដូវប្រាំងឆ្នាំ២០១៦-២០១៧ គិតត្រឹមថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ មានដូចតទៅ ៖

## I. **លទ្ធផលបញ្ចប់ការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៦ ៖**

### ១- ការងារដាំដុះ ៖

ក- ភ្ជួររាស់រៀបចំដីសម្រេចបានចំនួន ៣ ០០១ ០៨៥ហ.ត ក្នុងនោះ ភ្ជួររាស់ដោយគោក្របីចំនួន ២៦៥ ១០២ហ.ត (ស្មើនឹង ៨,៨៣%) និងដោយគ្រឿងយន្តកសិកម្មចំនួន ២ ៧៣៥ ៩៨៣ហ.ត (ស្មើនឹង ៩១,១៧%) តិចជាងឆ្នាំមុន៥៥២ ៨០២ហ.ត។

ខ- សាបសម្រេចបានចំនួន ៥០ ៦១៩ហ.ត តិចជាងឆ្នាំមុន ២០ ៤៥៤ហ.ត។

គ- ស្ទូងនិងព្រោះសម្រេចបានចំនួន ២ ៥៩៧ ៤១២ហ.ត ស្មើនឹង ១០៤,៨៨%នៃផែនការ ២ ៤៧៦ ៤៤៦ហ.ត លើសឆ្នាំមុន៣៥ ៤៥៤ហ.ត ស្មើនឹង ៥,០៨%។

### ២- ល្បឿនការងារប្រមូលផលស្រូវរដូវវស្សាឆ្នាំ២០១៦ (ដូចមានតារាងជូនភ្ជាប់) ៖

ការងារប្រមូលផលស្រូវរដូវវស្សា រហូតមកដល់ពេលនេះ សម្រេចបានចំនួន ៩១៧ ៨៦៥ហ.ត លើផ្ទៃដីអនុវត្តសរុប ២ ៥៩៧ ៤១២ហ.ត ដោយទទួលបានបរិមាណផលសរុបចំនួន ២ ៧៩៤ ៨៣៥តោន លើសឆ្នាំមុន ៤៦០ ៥៩៤តោន។ ទិន្នផលគិតជាមធ្យម ៣,០៤៥តោន/ហ.ត (សប្តាហ៍មុន ៣,២០៧តោន/ហ.ត) លើសឆ្នាំមុន ៨២គ.ក្រ/ហ.ត។

## II. **ល្បឿនការងារបង្កបង្កើនផលស្រូវរដូវប្រាំងឆ្នាំ២០១៦-២០១៧** (ដូចមានតារាងជូនភ្ជាប់) ៖

- លទ្ធផលភ្ជួររាស់រៀបចំដីសម្រេចបានចំនួន ១៥០ ៨៧៨ហ.ត តិចជាងឆ្នាំមុនចំនួន ៩៣ ៤២២ហ.ត ក្នុងនោះ ភ្ជួររាស់ដោយគោ ក្របីចំនួន ៥ ៩៣៣ហ.តស្មើនឹង ៣,៩៣% និងដោយគ្រឿងយន្តចំនួន ១៤៤ ៩៤៥ហ.តស្មើនឹង ៩៦,០៧%
- សាបបានសរុបចំនួន ១៥៦ហ.ត តិចជាងឆ្នាំមុនចំនួន ៥៧០ហ.ត
- ស្ទូងនិងព្រោះសម្រេចបានចំនួន ១០៥ ៥៥០ហ.ត ស្មើនឹង ២៤,៥៨%នៃផែនការ ៤២៩ ៣៥៥ហ.ត តិចជាងឆ្នាំមុន៨៨ ៣២១ហ.ត។

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
No. 200 , Preah Norodom Sangkat Tonle Basak Khan Chamkamon B V D, Phnom Penh. Cambodia
ទូរសព្ទ័លេខ : (០២៣) ៧២៦ ១២៨/៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 217-320

III. ល្បឿនការងារបង្កបង្កើនផលដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មរដូវប្រាំងឆ្នាំ២០១៦-២០១៧ (ដូចមានតារាងជូនភ្ជាប់)÷

ក- ផ្ទៃដីដំណាំរួមផ្សំ អនុវត្តបានចំនួន ៧ ៦៧៩ហ.ត ស្មើនឹង ១០,៤៨% នៃផែនការ ៧៣ ២៤៩ហ.ត តិចជាងឆ្នាំមុន ៥ ៥២៩ហ.ត។

ខ -ផ្ទៃដីដំណាំឧស្សាហកម្ម អនុវត្តបានចំនួន ៩៨៤ហ.ត ស្មើនឹង ៦,៩៧% នៃផែនការ ១៤ ១២១ហ.ត តិចជាងឆ្នាំមុន ២ ០៣៣ហ.ត។

## IV. សេចក្តីសន្និដ្ឋាន

ជារួមការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៦ បានបញ្ចប់ជាស្ថាពរហើយ ដោយសម្រេចបាន ២ ៥៩៧ ៤១២ហត ស្មើនឹង ១០៤,៨៨% នៃផែនការ ២ ៤៧៦ ៤៤៦ហត លើសឆ្នាំមុនចំនួន ៣៥ ៤៥៤ហត។ មកទល់ពេលនេះ ប្រជាកសិករបាននិងកំពុងជំរុញការងារប្រមូលផលដំណាំរដូវវស្សាយ៉ាងសកម្ម ក្នុងនោះ ល្បឿននៃការប្រមូលផលស្រូវរដូវវស្សាគឺស្មើនឹង ៣៥,៣៤% នៃផ្ទៃដីអនុវត្ត ២ ៥៩៧ ៤១២ហត ដែលទទួលបានទិន្នផលគិតជាមធ្យម ៣,០៤៥តោន/ហ.ត និងកំពុងខិតខំជំរុញការដាំដុះដំណាំរដូវប្រាំងជាបន្តទៅទៀត។ ទន្ទឹមនឹងនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានណែនាំជាប្រចាំដល់ថ្នាក់ដឹកនាំមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តទាំងអស់ត្រូវចាត់វិធានការគ្រប់គ្រងទឹកឱ្យមានប្រសិទ្ធភាព ព្រមទាំងជំរុញការជីកស្តារស្រះប្រឡាយ អាងស្តុកទឹក រក្សាទឹកទុកបង្ការការខ្វះខាតនៅចុងរដូវ។ ម្យ៉ាងទៀតក្នុងកាលៈទេសៈដែលកសិករកំពុងតែប្រមូលផលស្រូវចុងរដូវវស្សានេះ ក៏មានការបន្ទាបតម្លៃស្រូវនៅលើទីផ្សារដែលធ្វើឱ្យប៉ះពាល់ទៅលើចំណូលរបស់កសិករផងដែរហើយក្រសួងក៏បានណែនាំដល់អង្គភាពជំនាញពាក់ពន្ធ័ត្រូវសហការជាមួយអាជ្ញាធរមូលដ្ឋាន សហគមន៍ម៉ាស៊ីនកិនស្រូវនិងសហគមន៍កសិកម្មក្នុងការចូលរួមដោះស្រាយបញ្ហាប្រឈមទាំងអស់នេះ ដែលអាចកើតឡើងជាយថាហេតុនៅពេលខាងមុខ។ ទន្ទឹមនឹងនេះ ក្រសួងនឹងរៀបចំកិច្ចប្រជុំក្រុមការងារផ្នែកស្រូវ អង្ករ (ក្រុម "ឈ") នៃវេទិការាជរដ្ឋាភិបាលផ្នែកឯកជននៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ ខាងមុខនេះផងដែរ។ ដោយឡែក ក្រសួងបន្តចុះពិនិត្យតាមដានការចាក់វ៉ាក់សាំងការពារជំងឺឆ្លងសត្វផ្សេងៗ និងចាត់ក្រុមអន្តរាគមន៍ចុះទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានីខេត្តជាប់ជាប្រចាំ។

សេចក្តីដូចបានគោរពរាយការណ៍ជូនខាងលើនេះ ខ្ញុំបាទសូម **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ជាទីគោរពដ៏ខ្ពង់ខ្ពស់ មេត្តាជ្រាបដោយក្តីអនុគ្រោះ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅបំផុតអំពីខ្ញុំបាទ។

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**ចម្លងជូន ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  "ដើម្បីជូនជ្រាប"
- ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
  "ដើម្បីជ្រាប"
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

នាយកដ្ឋានផែនការ និង ស្ថិតិ

# ល្បឿនការងារប្រមូលផលស្រូវរដូវវស្សាឆ្នាំ ២០១៦

(គិតត្រឹមថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦)

| ល.រ | រាជធានី-ខេត្ត | ផ្ទៃដីអនុវត្ត (ហត) | ផ្ទៃដីប្រមូលផល (ហត) | ទិន្នផល (តោន/ហ.ត) | បរិមាណផល (តោន) | ភាគរយ (%) | ថ្ងៃខែរាយការណ៍ |
|---|---|---|---|---|---|---|---|
| 01 | បន្ទាយមានជ័យ | 247,015 | 121,041 | 2.845 | 344,369 | 49.00 | 21-11-2016 |
| 02 | បាត់ដំបង | 289,567 | 97,334 | 3.793 | 369,188 | 33.61 | 22-11-2016 |
| 03 | កំពង់ចាម | 89,861 | 24,609 | 3.503 | 86,212 | 27.39 | 17-11-2016 |
| 04 | កំពង់ឆ្នាំង | 124,409 | 10,650 | 2.878 | 30,649 | 8.56 | 22-11-2016 |
| 05 | កំពង់ស្ពឺ | 115,116 | 2,990 | 2.850 | 8,522 | 2.60 | 23-11-2016 |
| 06 | កំពង់ធំ | 215,526 | 80,519 | 2.607 | 209,906 | 37.36 | 22-11-2016 |
| 07 | កំពត | 138,388 | 25,011 | 3.712 | 92,841 | 18.07 | 21-10-2016 |
| 08 | កណ្តាល | 35,329 | 9,181 | 3.762 | 34,542 | 25.99 | 26-10-2016 |
| 09 | កោះកុង | 10,503 | 3,239 | 2.814 | 9,114 | 30.84 | 22-11-2016 |
| 10 | ក្រចេះ | 33,072 | 14,057 | 3.170 | 44,561 | 42.50 | 14-11-2016 |
| 11 | មណ្ឌលគិរី | 23,608 | 2,884 | 2.748 | 7,926 | 12.22 | 23-11-2016 |
| 12 | ភ្នំពេញ | 10,291 | 147 | 3.020 | 444 | 1.43 | 27-09-2016 |
| 13 | ព្រះវិហារ | 82,398 | 53,193 | 2.742 | 145,877 | 64.56 | 21-11-2017 |
| 14 | ព្រៃវែង | 270,111 | 110,766 | 3.195 | 353,871 | 41.01 | 22-11-2016 |
| 15 | ពោធិ៍សាត់ | 115,984 | 67,863 | 3.123 | 211,936 | 58.51 | 17-11-2016 |
| 16 | រតនគិរី | 24,011 | 13,627 | 2.200 | 29,979 | 56.75 | 17-11-2016 |
| 17 | សៀមរាប | 186,735 | 96,050 | 2.511 | 241,146 | 51.44 | 21-11-2016 |
| 18 | ព្រះសីហនុ | 16,605 | 2,693 | 2.110 | 5,683 | 16.22 | 21-11-2016 |
| 19 | ស្ទឹងត្រែង | 28,678 | 20,210 | 2.500 | 50,525 | 70.47 | 22-11-2016 |
| 20 | ស្វាយរៀង | 168,528 | 37,447 | 2.900 | 108,596 | 22.22 | 23-11-2016 |
| 21 | តាកែវ | 197,444 | 59,022 | 3.951 | 233,201 | 29.89 | 22-11-2016 |
| 22 | ឧត្តរមានជ័យ | 86,501 | 43,520 | 2.500 | 108,814 | 50.31 | 21-11-2016 |
| 23 | កែប | 3,597 | 761 | 2.327 | 1,771 | 21.16 | 22-11-2016 |
| 24 | ប៉ៃលិន | 5,825 | 1,616 | 2.800 | 4,525 | 27.74 | 23-11-2016 |
| 25 | ត្បូងឃ្មុំ | 78,310 | 19,435 | 3.120 | 60,637 | 24.82 | 18-11-2016 |
| សរុប | | 2,597,412 | 917,865 | 3.045 | 2,794,835 | 35.34 | |
| តួលេខសប្តាហ៍មុន | | 2,597,412 | 662,833 | 3.207 | 2,125,776 | 25.52 | |
| តួលេខឆ្នាំ២០១៥ | | 2,561,958 | 787,817 | 2.963 | 2,334,241 | 30.75 | |
| ប្រៀបធៀបឆ្នាំមុន | | 35,454 | 130,048 | 0.082 | 460,594 | 4.59 | |

បានឃើញនិងឯកភាព

ភ្នំពេញ, ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦

ជ- ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ

ជ- ប្រធានការិយាល័យស្ថិតិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
នាយកដ្ឋានផែនការ និង ស្ថិតិ

## ល្បឿនការងារបង្កបង្កើនផលស្រូវរដូវប្រាំងឆ្នាំ២០១៦-២០១៧

(គិតត្រឹមថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ )

| ល.រ | រាជធានី-ខេត្ត | ផែនការ (ហ.ត) | ផ្ទៃដក្ខរាស់ | | | | | ផ្ទៃដីសាប (ហ.ត) | ផ្ទៃដស្ទូង និងព្រោះ (ហត) | | | ភាគរយ | ថ្ងៃខែរាយការណ៍ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | សរុប (ហ.ត) | គោ-ក្របី | | គ្រឿងយន្ត | | | សន្ទូង | ពង្រោះ | សរុប | | |
| | | | | ហ.ត | % | ហ.ត | % | | | | | | |
| 01 | បន្ទាយមានជ័យ | 17,870 | 9,254 | - | - | 9,254 | 100.00 | 1 | 30 | 9,168 | 9,198 | 51.47 | 21-11-2016 |
| 02 | បាត់ដំបង | 12,000 | - | | | | - | | | | - | - | |
| 03 | កំពង់ចាម | 42,000 | 11,991 | 3,140 | 26.19 | 8,851 | 73.81 | 70 | 626 | 9,750 | 10,376 | 24.70 | 17-11-2015 |
| 04 | កំពង់ឆ្នាំង | 30,700 | 2,200 | - | - | 2,200 | 100.00 | - | - | 2,200 | 2,200 | 7.17 | 22-11-2016 |
| 05 | កំពង់ស្ពឺ | 550 | - | | - | | - | | | | - | - | |
| 06 | កំពង់ធំ | 36,000 | 9,800 | - | - | 9,800 | 100.00 | 9 | 142 | 9,658 | 9,800 | 27.22 | 22-11-2016 |
| 07 | កំពត | 7,000 | - | | - | | - | | | | - | - | |
| 08 | កណ្ដាល | 55,800 | 3,980 | 835 | 20.98 | 3,145 | 79.02 | - | - | 2,113 | 2,113 | 3.79 | 23-11-2016 |
| 09 | កោះកុង | - | - | | - | | - | | | | - | - | |
| 10 | ក្រចេះ | 14,000 | 14,370 | 1,444 | 10.05 | 12,926 | 89.95 | 21 | 62 | 7,971 | 8,033 | 57.38 | 14-11-2016 |
| 11 | មណ្ឌលគិរី | | - | | - | | - | | | | - | - | |
| 12 | ភ្នំពេញ | 1,150 | - | - | - | - | - | - | - | - | - | - | |
| 13 | ព្រះវិហារ | 130 | - | | - | | - | | | | - | - | |
| 14 | ព្រៃវែង | 75,000 | 21,600 | - | - | 21,600 | 100.00 | - | - | 21,600 | 21,600 | 28.80 | 22-11-2016 |
| 15 | ពោធិ៍សាត់ | 9,000 | 2,210 | - | - | 2,210 | 100.00 | - | - | 1,053 | 1,053 | 11.70 | 16-11-2016 |
| 16 | រតនៈគិរី | | - | | - | | - | | | | - | - | |
| 17 | សៀមរាប | 20,925 | 12,585 | - | - | 12,585 | 100 | - | - | 6,890 | 6,890 | 32.93 | 21-11-2016 |
| 18 | ព្រះសីហនុ | | - | | - | | - | | | | - | - | |
| 19 | ស្ទឹងត្រែង | 100 | - | | - | | - | | | | - | - | |
| 20 | ស្វាយរៀង | 20,000 | 20,000 | - | - | 20,000 | 100.00 | - | - | 20,000 | 20,000 | 100.00 | 16-11-2016 |
| 21 | តាកែវ | ·75,000 | 38,213 | 364 | 0.95 | 37,849 | 99.05 | - | - | 9,927 | 9,927 | 13.24 | 22-11-2016 |
| 22 | ឧត្ដរមានជ័យ | 600 | - | | - | | - | | | | - | - | |
| 23 | កែប | 30 | - | | - | | - | | | | - | - | |
| 24 | ប៉ៃលិន | 1,000 | - | | - | | - | | | | - | - | |
| 25 | ត្បូងឃ្មុំ | 10,500 | 4,675 | 150 | 3.21 | 4,525 | 96.79 | 55 | 335 | 4,025 | 4,360 | 41.52 | 11-11-2016 |
| | សរុប | 429,355 | 150,878 | 5,933 | 3.93 | 144,945 | 96.07 | 156 | 1,195 | 104,355 | 105,550 | 24.58 | |
| | តួលេខសប្តាហ៍មុន | 429,355 | 120,599 | 5,217 | 3.64 | 115,382 | 96.36 | 156 | 606 | 76,820 | 77,426 | 18.03 | |
| | តួលេខឆ្នាំមុន | 417,325 | 244,300 | 8,172 | 3.35 | 236,128 | 96.65 | 726 | 2,559 | 191,312 | 193,871 | 46.46 | |
| | ប្រៀបធៀបឆ្នាំមុន | 12,030 | -93,422 | -2,239 | 0.59 | -91,183 | -0.59 | -570 | -1,364 | -86,957 | -88,321 | | |

បានឃើញនិងឯកភាព
ជ- ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ

ភ្នំពេញ, ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦
ជ. ប្រធានការិយាល័យស្ថិតិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
នាយកដ្ឋានផែនការនិងស្ថិតិ

# ល្បឿនការងារបង្កបង្កើនផលដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មរដូវប្រាំងឆ្នាំ២០១៦-២០១៧

(គិតត្រឹមថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦)

| ល.រ | រាជធានី-ខេត្ត | ពោត (ហ.ត) | | | | ដំឡូងឈើ (ហ.ត) | | ដំឡូងជ្វា (ហ.ត) | | បន្លែគ្រប់មុខ (ហ.ត) | | សណ្តែកបាយ (ហ.ត) | | សរុបរួម (ហ.ត) | | ភាគរយ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ផែនការ | | អនុវត្ត | | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | % |
| | | សរុប | ក្រហម | សរុប | ក្រហម | | | | | | | | | | | |
| 01 | បន្ទាយមានជ័យ | 225 | - | | | 6,250 | | - | | 1,325 | 286 | 120 | 1 | 7,920 | 287 | 3.62 |
| 02 | បាត់ដំបង | 460 | | | | | | 50 | | 960 | | 300 | | 1,770 | - | - |
| 03 | កំពង់ចាម | 1,010 | 150 | 807 | 218 | 20 | - | 760 | 100 | 2,380 | 906 | 150 | 380 | 4,320 | 2,193 | 50.76 |
| 04 | កំពង់ឆ្នាំង | 1,090 | 170 | | | 90 | | 230 | | 1,860 | | 1,800 | | 5,070 | - | - |
| 05 | កំពង់ស្ពឺ | 4 | - | | | 0 | | 0 | | 190 | | 0 | | 194 | - | - |
| 06 | កំពង់ធំ | 130 | - | - | - | 90 | - | 60 | 45 | 345 | 61 | 20 | - | 645 | 106 | 16.43 |
| 07 | កំពត | 200 | - | | | 135 | | 245 | | 590 | | 255 | | 1,425 | - | - |
| 08 | កណ្តាល | 8,101 | 6,620 | | | 225 | | 190 | | 5,056 | | 4,307 | | 17,879 | - | - |
| 09 | កោះកុង | 27 | - | | | 3 | | 5 | | 60 | | - | | 95 | - | - |
| 10 | ក្រចេះ | 1,800 | 1,700 | 639 | 413 | - | | 80 | | 420 | 132 | 40 | 8 | 2,340 | 779 | 33.29 |
| 11 | មណ្ឌលគិរី | - | - | | | - | | - | | - | 474 | - | | - | 474 | - |
| 12 | ភ្នំពេញ | 130 | - | | | - | | - | | 342 | | - | | 472 | - | - |
| 13 | ព្រះវិហារ | - | - | | | - | | - | | 782 | | - | | 782 | - | - |
| 14 | ព្រៃវែង | 1,825 | 1,825 | | | 200 | | 10 | | 790 | | 1,425 | | 4,250 | - | - |
| 15 | ពោធិ៍សាត់ | 200 | 100 | 38 | | 850 | 34 | 350 | | 500 | 59 | 300 | 3 | 2,200 | 134 | 6.09 |
| 16 | រតនគិរី | | | | | | | | | | | | | - | - | - |
| 17 | សៀមរាប | 830 | - | | | 2,490 | | 265 | | 2,040 | | 1,850 | | 7,475 | - | - |
| 18 | ព្រះសីហនុ | 35 | | | | 140 | | 20 | | 175 | | | | 370 | - | - |
| 19 | ស្ទឹងត្រែង | 250 | - | 81 | | - | | - | 25 | 450 | 59 | 500 | | 1,200 | 165 | 13.75 |
| 20 | ស្វាយរៀង | | | | | 7,100 | | 110 | | 1,170 | | - | | 8,380 | - | - |
| 21 | តាកែវ | 232 | - | 109 | - | 398 | 1,698 | 110 | 397 | 648 | 842 | - | 169 | 1,388 | 3,215 | 231.63 |
| 22 | ឧត្តរមានជ័យ | 9 | - | | | 0 | | - | | 65 | | - | | 74 | - | - |
| 23 | កែប | 150 | 30 | | | 30 | 2 | 100 | | 200 | | - | | 480 | 2 | 0.42 |
| 24 | ប៉ៃលិន | 2,005 | 2,000 | 298 | - | 1,500 | | | | 15 | | 1,000 | 26 | 4,520 | 324 | 7.17 |
| 25 | ត្បូងឃ្មុំ | 5,210 | 8,942 | 375 | 345 | - | | 400 | 25 | 1,145 | 80 | 490 | 25 | 10,977 | 505 | 13,357 |
| | សរុប | 18,713 | 12,595 | 1,972 | 631 | 19,521 | 1,734 | 2,585 | 567 | 11,350 | 2,819 | 12,067 | 587 | 73,249 | 7,679 | 10.48 |
| | តួលេខសប្តាហ៍មុន | 18,713 | 12,595 | 1,779 | 568 | 19,521 | 1,732 | 2,585 | 511 | 11,350 | 2,488 | 12,067 | 524 | 73,249 | 7,034 | 9.60 |
| | តួលេខឆ្នាំមុន | 10,504 | 188 | 4,908 | 3,517 | 4,174 | 959 | 4,116 | 442 | 11,804 | 4,119 | 12,100 | 2,780 | 42,698 | 13,208 | 30.93 |
| | ប្រៀបធៀបឆ្នាំមុន | 8,209 | 12,407 | -2,936 | -2,886 | 15,347 | 775 | -1,531 | 125 | -454 | -1,300 | -33 | -2,193 | 30,551 | -5,529 | -20.45 |

| ល.រ | រាជធានី-ខេត្ត | សណ្តែកដី (ហ.ត) | | សណ្តែកសៀង (ហ.ត) | | ល្ង (ហ.ត) | | អំពៅ (ហ.ត) | | ក្រចៅ (ហ.ត) | | ថ្នាំជក់ (ហ.ត) | | សរុបរួម (ហ.ត) | | ភាគរយ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | (%) |
| 01 | បន្ទាយមានជ័យ | - | | - | | - | | 110 | | - | | - | | 110 | - | - |
| 02 | បាត់ដំបង | 100 | | | | 100 | | 30 | | | | | | 230 | - | - |
| 03 | កំពង់ចាម | 790 | 107 | - | - | 30 | 445 | 360 | - | - | - | 3,380 | - | 4,560 | 552 | 12.11 |
| 04 | កំពង់ឆ្នាំង | 80 | | | | 760 | | 60 | | 10 | | 60 | | 970 | - | - |
| 05 | កំពង់ស្ពឺ | 48 | | - | | - | | - | | - | | - | | 48 | - | - |
| 06 | កំពង់ធំ | 199 | | - | | - | | - | | - | | - | | 199 | - | - |
| 07 | កំពត | 205 | | - | | 30 | | 235 | | - | | - | | 470 | - | - |
| 08 | កណ្តាល | 96 | | 50 | | 150 | | 442 | | - | | - | | 738 | - | - |
| 09 | កោះកុង | - | | - | | - | | 340 | | - | | - | | 340 | - | - |
| 10 | ក្រចេះ | 120 | 5 | - | - | - | - | 110 | 89 | - | - | - | - | 230 | 94 | 40.87 |
| 11 | មណ្ឌលគិរី | - | | - | | - | | - | | - | | - | | - | - | - |
| 12 | ភ្នំពេញ | - | | - | | | | | | | | | | - | - | - |
| 13 | ព្រះវិហារ | - | | - | | - | | - | | - | | - | | - | - | - |
| 14 | ព្រៃវែង | 130 | | - | | 1,025 | | 175 | | - | | - | | 1,330 | - | - |
| 15 | ពោធិ៍សាត់ | 550 | | 50 | | 200 | | 720 | 20 | - | | - | | 1,520 | 20 | 1.32 |
| 16 | រតនគិរី | | | | | | | | | | | | | - | - | - |
| 17 | សៀមរាប | - | | 10 | | 210 | | 405 | | - | | - | | 625 | - | - |
| 18 | ព្រះសីហនុ | | | | | | | 40 | | | | | | 40 | - | - |
| 19 | ស្ទឹងត្រែង | - | | - | | | | | | | | | | - | - | |
| 20 | ស្វាយរៀង | | | | | | | 523 | | | | | | 523 | - | - |
| 21 | តាកែវ | 122 | 71 | - | | 11 | 17 | 175 | 220 | - | - | - | - | 308 | 308 | 100.00 |
| 22 | ឧត្តរមានជ័យ | - | | - | | - | | - | | - | | - | | - | - | - |
| 23 | កែប | 100 | | - | | - | | 30 | | - | | - | | 130 | - | - |
| 24 | ប៉ៃលិន | 50 | | | 5 | 100 | | 10 | | | | | | 160 | 5 | 3.13 |
| 25 | ត្បូងឃ្មុំ | 230 | 5 | - | - | - | | 20 | | - | | 1,340 | | 1,590 | 5 | 0.31 |
| | សរុប | 3,624 | 188 | 110 | 5 | 2,616 | 462 | 3,785 | 329 | 10 | - | 4,780 | - | 14,121 | 984 | 6.97 |
| | តួលេខសប្តាហ៍មុន | 3,624 | 183 | 110 | 5 | 2,616 | 395 | 3,785 | 329 | 10 | - | 4,780 | - | 14,121 | 912 | 6.46 |
| | តួលេខឆ្នាំមុន | 3,624 | 634 | 1,173 | 610 | 2,789 | 213 | 3,735 | 264 | 80 | - | 8,930 | 1,296 | 20,331 | 3,017 | 14.84 |
| | ប្រៀបធៀបឆ្នាំមុន | - | -446 | -1,063 | -605 | -173 | 249 | 50 | 65 | -70 | - | -4,150 | -1296 | -6,210 | -2033 | -7.87 |

បានឃើញ និងឯកភាព

ជ.-ប្រធាននាយកដ្ឋានផែនការ និងស្ថិតិ

ភ្នំពេញ, ថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០១៦

ជ.-ប្រធានការិយាល័យស្ថិតិ